# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

# ផែនការត្រៀមបម្រុងសម្រាប់ឆ្លើយតប
# សង្គ្រោះបន្ទាន់គ្រោះមហន្តរាយទឹកជំនន់
# ឆ្នាំ ២០២១

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានកំណត់ទិសដៅយុទ្ធសាស្ត្រ សម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយរបស់ប្រទេសកម្ពុជាសំដៅការពារ ការអភិវឌ្ឍ និងសុខុមាលភាពរបស់ប្រជាជន។

ព្រះរាជាណាចក្រកម្ពុជាត្រូវបានចាត់ទុកជាប្រទេសក្នុងចំណោមប្រទេសនានា ដែលងាយទទួលរងមុខសញ្ញាគ្រោះថ្នាក់ទឹកជំនន់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ហើយគ្រោះមហន្តរាយទឹកជំនន់គឺតែងតែជួបប្រទះញឹកញាប់ធ្វើឱ្យមានការខូចខាត បាត់បង់មានទំហំធំជាងបើប្រៀបទៅនឹងមុខសញ្ញាគ្រោះថ្នាក់ដទៃដែលកើតមាននៅក្នុងប្រទេស។

ដោយពិចារណាអំពីបរិបទនៃការគ្រប់គ្រងគ្រោះមហន្តរាយទឹកជំនន់ និងអនុវត្តកិច្ចព្រមព្រៀងភាពជាដៃគូ ស្តីពីការអនុវត្តរួមគ្នាសម្រាប់ការគ្រប់គ្រងវិបត្តិ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយរវាងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងអង្គការកម្មវិធីស្បៀងអាហារពិភពលោក គឺបានរៀបចំផែនការត្រៀមបម្រុងឆ្លើយតបសង្គ្រោះបន្ទាន់គ្រោះមហន្តរាយទឹកជំនន់នេះឡើង ដែលជាផែនទីបង្ហាញផ្លូវសម្រាប់ប្រតិបត្តិពេលមានគ្រោះមហន្តរាយទឹកជំនន់កើតឡើង។

គោលបំណងនៃផែនការនេះគឺ ការកំណត់ត្រៀមទុកជាស្រេចនូវយន្តការ និងធនធានរបស់ស្ថាប័នគិតទាំងកម្លាំងមនុស្ស សម្ភារៈ មធ្យោបាយគ្រប់ប្រភេទ ការផ្តល់ជំនួយសង្គ្រោះបន្ទាន់។ល។ ឱ្យសមស្របទៅនឹងតម្រូវការប្រជាជនរងគ្រោះដោយគ្រោះទឹកជំនន់ ពិសេសក្រុមងាយរងគ្រោះ ស្ត្រី កុមារ ចាស់ជរា ជនមានពិការភាព និងអ្នកទីទ័លក្រ ទទួលបាននូវសេវាសុខភាព ទឹកស្អាត អនាម័យ ជម្រកស្នាក់នៅបណ្តោះអាសន្ន ការអប់រំ ការការពារ និងស្បៀងអាហារ។ ព្រមជាមួយនេះក៏បានផ្តោតសំខាន់ទៅលើរបៀបចាត់ចែង ភ្ជាប់ទំនាក់ទំនងបញ្ជាការគ្រប់គ្រង ការប្រតិបត្តិ ការគាំទ្រ និងដំណោះស្រាយ។

មេរៀនដែលទទួលបានពីការអនុវត្តកន្លងមកបញ្ជាក់ថា ការគ្រប់គ្រងគ្រោះមហន្តរាយពុំមានស្ថាប័នណាមួយឯកឯងធ្វើបានឡើយគឺ ត្រូវការចាំបាច់ពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ចូលរួម ដែលត្រូវចាត់ទុកថាជាការងារយើងទាំងអស់គ្នាទើបសម្រេចបាន។ យើងខ្ញុំសង្ឃឹមថាក្រសួងស្ថាប័ន អង្គការពាក់ព័ន្ធជាតិ និងអន្តរជាតិ និងអ្នកពាក់ព័ន្ធនឹងធ្វើការជាមួយគ្នាតាមយុទ្ធសាស្ត្រនៃផែនការដោយរលូន និងការទទួលខុសត្រូវដែលជាកម្លាំងមិនអាចខ្វះបាន។

គួរបញ្ជាក់ផងដែរថាការធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ ផែនការត្រៀមបម្រុងសម្រាប់ឆ្លើយតបសង្គ្រោះបន្ទាន់គ្រោះមហន្តរាយទឹកជំនន់នេះគឺសំដៅសមស្របទៅនឹងស្ថានភាព នៃចរិតលក្ខណៈមុខ

សញ្ញាគ្រោះថ្នាក់ទឹកជំនន់ សមត្ថភាពក្នុងការទប់ទល់ និងដោះស្រាយសម្រាប់ឆ្លើយតបសង្គ្រោះបន្ទាន់មានប្រសិទ្ធភាពខ្ពស់។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាល រាជធានី-ខេត្ត អង្គការជាតិ អន្តរជាតិ និងភ្នាក់ងារសហប្រជាជាតិទាំងអស់ ដែលបានចូលរួមសហការធ្វើបច្ចុប្បន្នភាពផែនការត្រៀមបម្រុងសម្រាប់ឆ្លើយតបសង្គ្រោះបន្ទាន់គ្រោះមហន្តរាយទឹកជំនន់ ឆ្នាំ២០២១ នេះឡើង។

ថ្ងៃ ពុធ ៤ រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០២១

**គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ**

**អនុប្រធានទី១**

នាយឧត្តមសេនីយ៍ គន់ គីម

# មាតិការឿង


**១. សារបាន** ..... 3

១.១. បរិបទទូទៅ ..... 3

១.៣ កងកម្លាំង រុករក និងសង្គ្រោះថ្នាក់ជាតិ ..... 4

១.៤. បទពិសោធន៍និងមេរៀនពីគ្រោះមហន្តរាយទឹកជំនន់ក្នុងពេល១០ឆ្នាំកន្លងមក ..... 5

១.៥. ក្របខ័ណ្ឌគតិយុត្តិ និង យន្តការសម្របសម្រួលគ្រប់គ្រងគ្រោះមហន្តរាយ ..... 5

១.៦. គោលបំណងនៃផែនការ ..... 6

**២. សេណារីយ៉ូ និងការតាមដានហានិភ័យគ្រោះមហន្តរាយទឹកជំនន់** ..... 6

២.១. កត្តាប្រឈមនៃគ្រោះទឹកជំនន់ ..... 6

២.២. កម្រិតសេណារីយ៉ូ ..... 7

២.៣. ព័ត៌មានព្យាករណ៍ពីស្ថានភាពគ្រោះទឹកជំនន់ឆ្នាំ ២០២១ ..... 9

២.៤. សេណារីយ៉ូ គ្រោះមហន្តរាយទឹកជំនន់ ..... 9

**៣. យុទ្ធសាស្ត្រឆ្លើយតប/ជម្រើសសម្រាប់ការអន្តរាគមន៍** ..... 11

៣.១ គោលបំណង ..... 11

៣.២ លទ្ធផលរំពឹងទុក ..... 12

៣.៣. នីតិវិធីប្រតិបត្តិស្តង់ដារឆ្លើយតប សង្គ្រោះបន្ទាន់របស់ គ.ជ.គ.ម. ..... 12

៣.៣.១ លក្ខណៈវិនិច្ឆ័យសម្រាប់ការចាប់ផ្តើមអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដាតាមដំណាក់កាល ..... 13

៣.៣.១.១ ដំណាក់កាលប្រកាសអាសន្ន/ត្រៀមរៀបចំ ..... 13

៣.៣.១.២ ដំណាក់កាលឆ្លើយតបសង្គ្រោះបន្ទាន់គ្រោះមហន្តរាយទឹកជំនន់កម្រិតជាតិ ..... 13

៣.៣.១.៣. ដំណាក់កាលបិទបញ្ចប់ប្រតិបត្តិការឆ្លើយតបសង្គ្រោះបន្ទាន់ ..... 14

៣.៤. ការអនុវត្តដំណាក់កាលនីមួយៗនៃនីតិវិធីប្រតិបត្តិស្តង់ដា គ.ជ.គ.ម. ..... 14

៣.៤.១. ដំណាក់កាលប្រកាសអាសន្ន/ត្រៀមរៀបចំ (មុនពេលទឹកជំនន់) ..... 14

៣.៤.២. ដំណាក់កាលឆ្លើយតប សង្គ្រោះបន្ទាន់គ្រោះមហន្តរាយទឹកជំនន់ ..... 17

៣.៤.៣. ដំណាក់កាលបិទបញ្ចប់ប្រតិបត្តិការ ឆ្លើយតបសង្គ្រោះបន្ទាន់ ..... 20

៣.៥. ការឆ្លើយតបតាមវិស័យ ..... 21

៣.៥.១. វិស័យស្បៀងអាហារ និងអាហារូបត្ថម្ភ ..... 21

៣.៥.២. វិស័យជម្រក ..... 22

៣.៥.៣. វិស័យសុខភាព ..... 24

៣.៥.៤. វិស័យទឹកស្អាត និងអនាម័យ.....25

៣.៥.៥ វិស័យការពារ រុករកនិងសង្គ្រោះ.....27

៣.៥.៦. វិស័យអប់រំ.....28

**៤. ធនធានត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយទឹកជំនន់.....30**

៤.១. ធនធានដែលមានស្រាប់.....30

៤.២. ធនធានដែលអាចកៀរគរបាន.....30

៤.៣. ទីទួលសុវត្ថិភាព.....30

**៥. យន្តការសម្របសម្រួលឆ្លើយតបសង្គ្រោះបន្ទាន់គ្រោះមហន្តរាយទឹកជំនន់ជាមួយស្ថាប័នពាក់ព័ន្ធ.....31**

**៦. ឧបសម្ព័ន្ធ.....32**

ឧបសម្ព័ន្ធទី១៖ រចនាសម្ព័ន្ធក្រុមការងារប្រតិបត្តិឆ្លើយតបគ្រោះមហន្តរាយនិងការទទួលខុសត្រូវតាមផ្នែក.....33

ឧបសម្ព័ន្ធ២៖ វេទិកា និងបណ្តាញការងារគ្រប់គ្រងគ្រោះមហន្តរាយ.....36

ឧបសម្ព័ន្ធទី៣៖ សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារសម្របសម្រួលការគ្រប់គ្រងគ្រោះមហន្តរាយ និងក្រុមការងារអន្តរាគមន៍ប្រតិបត្តិការរុករកនិងសង្គ្រោះគ្រោះមហន្តរាយរបស់ គ.ជ.គ.ម......37

ឧបសម្ព័ន្ធទី ៤៖ បញ្ជីរាយនាមថ្នាក់ដឹកនាំគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ.....42

ឧបសម្ព័ន្ធទី ៥៖ បញ្ជីរាយនាម គគមខ រាជធានី ខេត្ត ទាំង២៥.....43

ឧបសម្ព័ន្ធទី ៦៖ បញ្ជីរាយនាមមន្ត្រីទទួលបន្ទុកលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយក្រសួង/ស្ថាប័ននានា.....48

ឧបសម្ព័ន្ធទី ៧៖ បញ្ជីរាយនាមភ្នាក់ងារអង្គការដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិដែលពាក់ព័ន្ធ.....52

ឧបសម្ព័ន្ធទី ៨៖ បញ្ជីឈ្មោះសហគ្រាស និង សិប្បកម្ម.....59

**ឯកសារយោង.....62**

# ១. សារបាន

## ១.១. បរិបទទូទៅ

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយក្នុងចំណោមប្រទេសនៅអាស៊ីអាគ្នេយ៍ដែលរងគ្រោះ ដោយសារមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិរួមមាន ទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ រន្ទះបាញ់ ។ល។ ឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុក៏ជាកត្តាជំរុញ ឱ្យមុខសញ្ញាគ្រោះថ្នាក់ទាំងនោះឱ្យកាន់តែកើនឡើងនូវភាពញឹកញាប់ និងផលប៉ះពាល់ថែមមួយកម្រិតទៀត ។

ប្រជាជនកម្ពុជាភាគច្រើន ជាកសិករមានមុខរបរចិញ្ចឹមជីវិតដោយពឹងអាស្រ័យលើការដាំដុះនិងការនេសាទ។ ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ ភាពងាយរងគ្រោះរបស់ប្រជាជនកាន់តែកើនឡើងក្នុងកម្រិតខ្ពស់គួរឱ្យព្រួយបារម្ភ ដែលទាមទារឱ្យមានផែនការត្រៀមបម្រុងសម្រាប់ឆ្លើយតបដែលមានប្រសិទ្ធភាពខ្ពស់។

តាមរយៈការប្រមូលព័ត៌មានទាក់ទងនឹងមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ នៅទីតាំងខេត្តក្រុងចំនួន ២៤ (មិនបានរាប់បញ្ចូលរាជធានីភ្នំពេញ) និងសិក្ខាសាលាវិភាគអំពីកម្រិតហានិភ័យគ្រោះមហន្តរាយដែលបានធ្វើឡើងដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្ត នៅថ្ងៃទី ២១-២២ ខែ ឧសភា ឆ្នាំ ២០២០ នៅទីរួមខេត្តកំពង់ស្ពឺ បានបង្ហាញថាគ្រោះមហន្តរាយដែលតែងតែកើតឡើងគួរឱ្យបារម្ភជាងគេនោះគឺ ទឹកជំនន់ ដែលធ្វើឱ្យប៉ះពាល់ដល់អាយុជីវិតមនុស្ស សត្វ ខូចខាតផ្ទះសម្បែង ទ្រព្យសម្បត្តិ ផលដំណាំ ស្បៀង ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ សាលារៀន និងវត្តអារាម ជាពិសេសបានធ្វើឱ្យប៉ះពាល់ដល់ការប្រកបមុខរបរចិញ្ចឹមជីវិតក៏ដូចជាប្រាក់ចំណូលផងដែរ ។ល។

រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ជាសំខាន់លើការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដោយការពារអាយុជីវិត ទ្រព្យសម្បត្តិ ជាមួយគ្នានោះគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ភ្នាក់ងារអភិវឌ្ឍន៍សហប្រជាជាតិ អង្គការជាតិ អង្គការអន្តរជាតិ សប្បុរសជន និងដៃគូអភិវឌ្ឍន៍ បានសហការគ្នាយ៉ាងជិតស្និទ្ធហើយបានអន្តរាគមន៍ឆ្លើយតប ពេលកើតមានគ្រោះមហន្តរាយម្តងៗ ជាក់ស្តែងគ្រោះទឹកជំនន់នាពេលកន្លងមក ។

ដោយផ្អែកលើការវិភាគអំពីកម្រិតហានិភ័យគ្រោះមហន្តរាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា បានបង្ហាញថា ក្នុងចំណោមមុខសញ្ញាគ្រោះថ្នាក់និងគ្រោះមហន្តរាយដែលបានកើតឡើង ទឹកជំនន់ គឺមានកម្រិតហានិភ័យខ្ពស់ជាងគេដែលជាកត្តាជម្រុញឱ្យគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានសម្រេចកំណត់អាទិភាពក្នុងការបង្កើតឡើងនូវផែនការត្រៀមបម្រុងសម្រាប់ឆ្លើយតប សង្គ្រោះបន្ទាន់គ្រោះមហន្តរាយទឹកជំនន់ ដើម្បីប្រើប្រាស់សម្រាប់ជាផែនទីបង្ហាញផ្លូវក្នុងការសម្រេចចិត្ត និងជាមូលដ្ឋានក្នុងការឆ្លើយតបសង្គ្រោះបន្ទាន់មួយឱ្យមានប្រសិទ្ធភាព និងអាចអនុវត្តបាន នៅពេលដែលគ្រោះមហន្តរាយទឹកជំនន់បានកើតឡើង។

ខាងក្រោមគឺជាស្ថានភាពទូទៅ និងផែនទីនៃមុខសញ្ញាគ្រោះថ្នាក់ទឹកជំនន់នៅក្នុងព្រះរាជាណាចក្រកម្ពុជា៖

- ចំនួនគ្រួសារសរុបអាចប៉ះពាល់ ៖១,៥៧០,៦១៩ គ្រួសារ
- ចំនួនគ្រួសារក្រីក្រសរុប ៖ ២៥៥,៥៨៩ គ្រួសារ
- ចំនួនរាជធានី-ខេត្តអាចប៉ះពាល់ ៖ ២៥
- បរិមាណផ្ទៃដីដំណាំស្រូវអាចប៉ះពាល់ ៖ ៨៦២,៨៩៤ ហិកតា
- ប្រវែងខ្សែផ្លូវជាតិចម្បងអាចប៉ះពាល់ ៖ ១៣៦,១៦៧ ម៉ែត្រ

- ប្រវែងខ្សែផ្លូវជាតិអាចប៉ះពាល់ ៖ ៧២,៦៥៦ ម៉ែត្រ
- ប្រវែងខ្សែផ្លូវខេត្តចម្បងអាចប៉ះពាល់ ៖ ១៣៥,៩១២ ម៉ែត្រ
- ប្រវែងខ្សែផ្លូវខេត្ត និងជនបទអាចប៉ះពាល់ ៖ ១,៥៥៩,២២ ម៉ែត្រ
- ចំនួនអណ្តូងតូចអាចប៉ះពាល់ ៖ ៤,២០៧ អណ្តូង
- ចំនួនសាលារៀនអាចប៉ះពាល់ ៖ ៥៩៦ ខ្នង




## ១.២ ប្រព័ន្ធស្បៀងបម្រុងថ្នាក់ជាតិ[1]

ដោយយោងលើអនុក្រឹត្យ ២១៨ អនក្រ បក ប្រព័ន្ធស្បៀងបម្រុងកម្ពុជា ២០១៦ ដែលបានរៀបចំ ឡើង ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានចំនួនបរិមាណដូចខាងក្រោម៖

- អង្ករ (អង្ករសុទ្ធ) ៖ ១០.០០០ តោន
- អង្ករ (រក្សាទុកជាថវិកា) ៖ ៦.០០០ តោន
- គ្រាប់ពូជស្រូវ ៖ ២.០០០ តោន
- គ្រាប់ពូជ (រក្សាទុកជាថវិកា) ៖ ១.០០០ តោន
- គ្រាប់ពូជបន្លែ ៖ ២៥ តោន

## ១.៣ កងកម្លាំង រុករក និងសង្គ្រោះថ្នាក់ជាតិ

កងកម្លាំងរុករក និងសង្គ្រោះដែលរៀបចំ បណ្តុះបណ្តាល និងបំពាក់នូវឧបករណ៍ បរិក្ខារ ដោយ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានចំនួនសរុប **១៦ កង** ដែលមានសមាជិកសរុបចំនួន

[1] អនុក្រឹត្យ ២១៨ អនក្រ បក ប្រព័ន្ធស្បៀងបម្រុងកម្ពុជា ២០១៦

**១៩២០ រូប**។ ខាងក្រោមនេះ គឺជាផែនទីបង្ហាញទីតាំងក្រុមកងរុករក និងសង្គ្រោះទាំង ១៦កង ដែលត្រៀមសម្រាប់សង្គ្រោះបន្ទាន់គ្រោះមហន្តរាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ផែនទីបង្ហាញពីកងប្រតិបត្តិការរុករក និងសង្គ្រោះគ្រោះមហន្តរាយរបស់ គ.ជ.គ.ម.**




## ១.៤. បទពិសោធន៍និងមេរៀនពីគ្រោះមហន្តរាយទឹកជំនន់ក្នុងពេល១០ឆ្នាំកន្លងមក

ទសវត្សរ៍ចុងក្រោយនេះ ព្រះរាជាណាចក្រកម្ពុជាបានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារគ្រោះទឹកជំនន់ ក្នុងឆ្នាំ ២០១១ ឆ្នាំ២០១៣ ឆ្នាំ២០១៨ និងឆ្នាំ ២០២០ ។ ផលប៉ះពាល់ទាំងនោះបានធ្វើឱ្យខូចខាតសម្បត្តិសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ កសិកម្ម ហើយប្រជាពលរដ្ឋរាប់លាននាក់ជួបការលំបាកក្នុងការប្រកបរបរចិញ្ចឹមជីវិត បាត់បង់ជម្រក និងធ្វើចំណាកស្រុកក្នុងករណីខ្លះ។

## ១.៥. ក្របខ័ណ្ឌគតិយុត្តិ និង យន្តការសម្របសម្រួលគ្រប់គ្រងគ្រោះមហន្តរាយ

- ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៧១៥/០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥។
- ផែនការថ្នាក់ជាតិស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឆ្នាំ ២០១៩ - ២០២៣
- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣។ គោលការណ៍សំខាន់នៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ គឺ ប្រមូលផ្តុំការចូលរួមធ្វើសកម្មភាពឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ដើម្បីការពារអាយុជីវិតប្រជាជន ជីវភាពរស់នៅ សុខភាព វប្បធម៌ គេហដ្ឋាន បរិស្ថាន ទ្រព្យសម្បត្តិ និងប្រព័ន្ធអេកូឡូស៊ីពីឥទ្ធិពលនៃមុខសញ្ញាគ្រោះថ្នាក់គ្រោះមហន្តរាយ
- ក្របខ័ណ្ឌការងារសេនដាយ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០១៥-២០៣០ ត្រូវបានអនុម័តនៅក្នុងសន្និសីទពិភពលោកលើកទី៣ នៃអង្គការសហប្រជាជាតិ នៅទីក្រុងសេនដាយ ខេត្តមីយ៉ាហ្គី ប្រទេសជប៉ុននាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥

- កិច្ចព្រមព្រៀងស្តីពីការប្រែប្រួលអាកាសធាតុនៅទីក្រុងប៉ារីស ឆ្នាំ២០១៥ ជាគោលការណ៍ណែនាំឱ្យប្រទេសនីមួយៗមានភារកិច្ចទទួលខុសត្រូវជាចម្បងដើម្បីការពារនិងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ រួមទាំងការ បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈកិច្ចសហប្រតិបត្តិការទ្វេភាគី អន្តរជាតិ តំបន់ អនុតំបន់ និងឆ្លងដែន។
- កិច្ចព្រមព្រៀងអាស៊ានស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងការឆ្លើយតបសង្គ្រោះបន្ទាន់ ដែលមានគោលដៅ គឺផ្តល់ជូននូវយន្តការប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចការកាត់បន្ថយជាសំខាន់នូវការបាត់បង់អាយុជីវិតមនុស្ស តាមរយៈកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ រួមសហប្រតិបត្តិការជាមួយថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ។
- សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារសម្របសម្រួលការគ្រប់គ្រងគ្រោះមហន្តរាយ និងក្រុមការងារអន្តរាគមន៍ប្រតិបត្តិការរុករកនិងសង្គ្រោះគ្រោះមហន្តរាយរបស់ គ.ជ.គ.ម. លេខ ១៤៩ សសរ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩

## ១.៦. គោលបំណងនៃផែនការ

គោលបំណងចម្បងរបស់ផែនការត្រៀមបម្រុងនេះ គឺដើម្បីធានាថាការរៀបចំជាមុនគ្រោះមហន្តរាយបានត្រឹមត្រូវសមរម្យ និងគ្រប់គ្រាន់ជាក់លាក់ ដើម្បីឆ្លើយតបឱ្យបានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព និងសមស្របទៅនឹងតម្រូវការរបស់មូលដ្ឋាននិងប្រជាជនដែលរងផលប៉ះពាល់។ ផែនការត្រៀមបម្រុងនេះ ក៏ជាផែនទីបង្ហាញផ្លូវសម្រាប់ការធ្វើសេចក្តីសម្រេច និងជាមូលដ្ឋានក្នុងការបង្កើតនូវផែនការឆ្លើយតបសង្គ្រោះបន្ទាន់នៅពេលដែលគ្រោះមហន្តរាយទឹកជំនន់បានកើតឡើង និងក៏មានគោលបំណងធ្វើឱ្យប្រសើរឡើងនិងកែលម្អនូវការសម្របសម្រួល និងការគាំទ្ររបស់រាជរដ្ឋាភិបាលក្នុងការដោះស្រាយ ពេលមានគ្រោះមហន្តរាយធំៗ។ ផែនការនេះក៏ស្ថិតនៅក្នុងក្របខ័ណ្ឌទូលំទូលាយនៃគោលការណ៍ត្រៀមរៀបចំឆ្លើយតបសង្គ្រោះបន្ទាន់។

# ២. សេណារីយ៉ូ និងការតាមដានហានិភ័យគ្រោះមហន្តរាយទឹកជំនន់

## ២.១. កត្តាប្រឈមនៃគ្រោះទឹកជំនន់

ជាក់ស្តែង គ្រោះមហន្តរាយទឹកជំនន់ឆ្នាំ២០១៣ បានបង្កឱ្យមានផលប៉ះពាល់ដល់ខេត្តចំនួន២០ ហើយមានប្រជាជនចំនួន ៣៧៧.៣៥៤ គ្រួសារដែលទទួលរងផលប៉ះពាល់ ប្រជាជនដែលត្រូវជម្លៀស ១៤៤.០០០ នាក់ ស្លាប់ ១៦៨ នាក់ ខូចខាតសាលារៀនចំនួន ១.០០០ កន្លែង ហេដ្ឋារចនាសម្ព័ន្ធ ២.៤២៤ គីឡូម៉ែត្រ និងខូចខាតស្រូវ ២៤៥.០០០ ហិកតា។ នៅក្នុងឆ្នាំ២០១៩ ដែលមានប្រជាជនចំនួន ៩៣.៣១៩ គ្រួសារត្រូវបានរងផលប៉ះពាល់ ក្នុងនោះមានប្រជាជនយ៉ាងតិចចំនួន ១១.៥៧៩គ្រួសារត្រូវជម្លៀស និងស្លាប់ ១៦នាក់ ប៉ះពាល់ផ្ទះសំបែងចំនួន ៨៣.៩៤២ ខ្នង មណ្ឌលសុខភាព ៣៤កន្លែង សាលារៀនចំនួន៣៥៩កន្លែង ខូចខាតហេដ្ឋារចនាសម្ព័ន្ធ ៩៧១.១៤៣ ម៉ែត្រ និងប៉ះពាល់ដល់ដំណាំកសិកម្មចំនួន ៥១.៨២៤ ហិកតា។ ខេត្តដែលប្រឈមនឹងបញ្ហាគ្រោះទឹកជំនន់ចុងក្រោយនៅក្នុងឆ្នាំ២០២០ មានដូចជា ខេត្តរតនគីរី ព្រះវិហារ ស្ទឹងត្រែង ក្រចេះ កំពង់ចាម ត្បូងឃ្មុំ ព្រៃវែង កំពង់ធំ បាត់ដំបង ពោធិសាត់ និងបន្ទាយមានជ័យ។

## ២.២. កម្រិតសេណារីយ៉ូ

**- ការកំណត់កម្រិតនៃហានិភ័យគ្រោះមហន្តរាយនៅក្នុងប្រទេសកម្ពុជា**

ការកំណត់រកកម្រិតហានិភ័យមុខសញ្ញាគ្រោះថ្នាក់នីមួយៗ បានធ្វើឡើងក្នុងគោលបំណងបញ្ជាក់ឱ្យកាន់តែច្បាស់ថាមុខសញ្ញាគ្រោះថ្នាក់មួយណា ដែលមានកម្រិតហានិភ័យខ្ពស់ជាងគេដែលតម្រូវជ្រើសរើសសម្រាប់រៀបចំផែនការត្រៀមបម្រុងសម្រាប់ឆ្លើយតបសង្គ្រោះបន្ទាន់ឱ្យបានប្រសើរ។

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់និយមន័យ[2] គ្រោះមហន្តរាយគឺសំដៅដល់ការរំខានដ៏ធ្ងន់ធ្ងរនៃដំណើរការសហគមន៍ ឬសង្គមដែលធ្វើឱ្យមានការបាត់បង់ និងប៉ះពាល់ធ្ងន់ធ្ងរដែលមនុស្ស សម្ភារៈ សេដ្ឋកិច្ច ឬបរិស្ថាន ហើយកម្រិតនៃការប៉ះពាល់ហួសពីលទ្ធភាពរបស់សហគមន៍ឬសង្គមដែលទទួលរងការប៉ះពាល់ ប្រើប្រាស់លៃលកដោះស្រាយដោយធនធានខ្លួនឯង។

**លក្ខណៈវិនិច្ឆ័យ**[3]៖

- បង្កការខូចខាត ប៉ះពាល់ដល់អាយុជីវិត និងរបួស ៥% នៃប្រជាពលរដ្ឋសរុបក្នុងតំបន់រដ្ឋបាល។
- ប៉ះពាល់ជាង៣០%នៃប្រជាពលរដ្ឋសរុបក្នុងតំបន់រដ្ឋបាល។
- បង្កការខូចខាតដល់ទ្រព្យសម្បត្តិ សំណង់ និងសេវាកម្មសាធារណៈដែលមិនអាចជួសជុលឡើងវិញបានក្នុងរយៈពេលមួយសប្តាហ៍។
- កាត់ផ្តាច់សេវាផ្គត់ផ្គង់ថាមពល ទូរគមនាគមន៍ ការផ្គត់ផ្គង់ទឹកស្អាត ដែលមិនអាចជួសជុលបានក្នុងរយៈពេលមួយសប្តាហ៍។

តារាងខាងក្រោមនេះ បង្ហាញអំពីលទ្ធផលនៃការពិភាក្សា ស្តីពីកម្រិតនៃហានិភ័យដែលផ្អែកលើលទ្ធផលនៃការប្រមូលព័ត៌មានហានិភ័យធំៗ (ភវនីយភាព "ភាពដែលអាចកើតឡើង" ផលប៉ះពាល់ និងទំហំប៉ាន់ស្មានផលប៉ះពាល់របស់វា) ដោយមានការចូលរួមពីតំណាងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្ត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

---

[2] និយមន័យដកស្រង់ពីសន្ធានុក្រមក្នុងឧបសម្ព័ន្ធច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ

[3] គោលការណ៍ណែនាំស្តីពី ផែនការត្រៀមបម្រុងសម្រាប់ឆ្លើយតបគ្រោះមហន្តរាយឆ្នាំ ២០១២ អនុម័តដោយ នាយករដ្ឋមន្ត្រី ទំព័រទី២៣

## - តារាងម៉ាទ្រីកកម្រិតហានិភ័យទឹកជំនន់[4]

| កម្រិតផលប៉ះពាល់ | | | | | | |
|---|---|---|---|---|---|---|
| | ៥.ធ្ងន់ធ្ងរបំផុត | | | | | |
| | ៤. ធ្ងន់ធ្ងរ | | | ជំនន់រហ័ស | | |
| | ៣. មធ្យម | | | | ជំនន់ទឹកទន្លេ | |
| | ២. ស្រាល | | | | | |
| | ១. តិចតួច | | | | | |
| | | ១. មិនទំនងកើតឡើងសោះ | ២. មិនទំនងកើតឡើង | ៣. ទំនងជាកើតឡើងមធ្យម | ៤. ទំនងជាកើតឡើងខ្លាំង | ៥. ទំនងជាកើតឡើងខ្លាំងណាស់ |
| | | ភវនីយភាព (ភាពដែលអាចកើតឡើង) | | | | |

| កម្រិតនៃផលប៉ះពាល់ (គ្រួសារ) ៖ | | ភវនីយភាព៖ | |
|---|---|---|---|
| ១. តិចតួច | (០០% -០៥%) | ១. មិនទំនងជាកើតឡើងសោះ | (០០% -២០%) |
| ២. ស្រាល | (០៦% -១០%) | ២. មិនទំនងកើតឡើង | (២១% -៤០%) |
| ៣. មធ្យម | (១១% -២០%) | ៣.ទំនងជាកើតឡើងមធ្យម | (៤១% -៦០%) |
| ៤. ធ្ងន់ធ្ងរ | (២១% -៣០%) | ៤. ទំនងជាកើតឡើងខ្លាំង | (៦១% -៨០%) |
| ៥. ធ្ងន់ធ្ងរបំផុត | (៣១% ឡើងទៅ) | ៥. ទំនងជាកើតឡើងខ្លាំងណាស់ | (៨១%-១០០%) |

## - ការកំណត់កម្រិតឆ្លើយតបហានិភ័យសម្រាប់ផែនការត្រៀមបម្រុងសម្រាប់ឆ្លើយតបគ្រោះអាសន្ន[5]

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្ត ត្រូវជូនដំណឹងជាបន្ទាន់ដល់ គ.ជ.គ.ម. ដើម្បីសុំយោបល់ និងការជួយអន្តរាគមន៍ ឬចលនាជំនួយមនុស្សធម៌ដើម្បីធ្វើការឆ្លើយតប នៅពេលដែលវិសាលភាពនៃគ្រោះមហន្តរាយហួសពីសមត្ថភាពនឹងលទ្ធភាពឆ្លើយតបរបស់ខ្លួន(មាត្រា ២២)។

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម.) ត្រូវជួបប្រជុំគ្រប់ភាគីពាក់ព័ន្ធ ពិភាក្សាអំពីការឆ្លើយតប លើកជាសំណើ និងវិធានការចាំបាច់នានាជូនដល់រាជរដ្ឋាភិបាលដើម្បីធ្វើសេចក្តីសម្រេចប្រកាសអំពីគ្រោះមហន្តរាយ និងចាត់វិធានការនានាទាក់ទងនឹងប្រតិបត្តិការសង្គ្រោះបន្ទាន់និងការឆ្លើយតបគ្រោះមហន្តរាយ (មាត្រា ២០)។

ការកំណត់កម្រិតហានិភ័យសម្រាប់ផែនការត្រៀមបម្រុងសម្រាប់ឆ្លើយតបគ្រោះអាសន្ន មានសារៈសំខាន់បំផុត សម្រាប់ជាជំនួយដល់ការធ្វើការសម្រេចចិត្តក្នុងការចាប់ផ្តើមធ្វើអន្តរាគមន៍ពីថ្នាក់ជាតិ ក្នុងការជួយសង្គ្រោះជនរងគ្រោះដោយសារគ្រោះមហន្តរាយ។ ដោយផ្អែកលើសំណើអន្តរាគមន៍ពីថ្នាក់រាជធានី ខេត្ត គឺជាកត្តាចង្អុលបង្ហាញមួយក្នុងចំណោមកត្តាចង្អុលបង្ហាញជាច្រើនទៀតដែលគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះ

[4] លទ្ធផលនេះបានពីការពិភាក្សាដោយមានការចូលរួមពី គ.គ.ម.ខ. ចំនួន ២៤ រាជធានី/ខេត្ត នៅថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០២០ ខេត្តកំពង់ស្ពឺ

[5] មាត្រាទាំងនេះគឺដកស្រង់ចេញពីច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ

មហន្តរាយអាចជ្រើសរើសសម្រាប់ជាសូចនាករ ក្នុងការធ្វើការសម្រេចចិត្តស្នើដល់រាជរដ្ឋាភិបាលដើម្បីដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន[6] ។ ការកំណត់កម្រិតហានិភ័យគ្រោះមហន្តរាយថ្នាក់ជាតិត្រូវបានចែកចេញជា៣កម្រិតដូចខាងក្រោម៖

| កម្រិតទី១ | កម្រិតទី ២ | កម្រិតទី៣ |
|---|---|---|
| ≤ ៤ខេត្ត<br>គ.ខ.គ.ម. ស្នើជួយអន្តរាគមន៍<br>ពី គ.ជ.គ.ម. | < ៤ ≤១០ខេត្ត<br>គ.ខ.គ.ម. ស្នើជួយអន្តរាគមន៍<br>ពី គ.ជ.គ.ម. | > ១០ ខេត្ត<br>គ.ខ.គ.ម. ស្នើជួយអន្តរាគមន៍<br>ពី គ.ជ.គ.ម. |

## ២.៣. ព័ត៌មានព្យាករណ៍ពីស្ថានភាពគ្រោះទឹកជំនន់ឆ្នាំ ២០២១

ប្រភពព័ត៌មានបែបវិទ្យាសាស្ត្រមួយចំនួនខាងក្រោម បានបញ្ជាក់ពីលទ្ធភាពនៃការកើតមានគ្រោះទឹកជំនន់ ក្នុងរដូវវស្សាឆ្នាំ ២០២១នេះ៖

- ក្រសួងធនធានទឹកនិងឧតុនិយមចេញសេចក្តីជូនដំណឹងអំពីស្ថានភាពធាតុអាកាសអំពីការវិវត្ត និងប្រែប្រួលជាពិសេសបញ្ហាភ្លៀង ផ្គររន្ទះ និងជ្រលងសម្ពាធទាប ដែលអាចនឹងមានឥទ្ធិពលគំរាមកំហែងដល់ព្រះរាជាណាចក្រកម្ពុជា។ http://www.cambodiameteo.com
- របាយការណ៍ស្តីពីសន្ទស្សន៍កម្រិតទឹកភ្លៀងក្នុងរយៈពេល៣ខែ នៅក្នុងខេត្តដែលមានក្នុងប្រព័ន្ធព្រីសឹម។ https://www.prism-kh.info/
- របាយការណ៍ស្តីពីសីតុណ្ហភាពលើផ្ទៃដីជាមធ្យម ក្នុងរយៈពេល៥ថ្ងៃ នៅក្នុងខេត្តដែលមានក្នុងប្រព័ន្ធព្រីសឹម។ https://www.prism-kh.info/
- តារាងព្យាករណ៍ របស់គណៈកម្មាធិការទន្លេមេគង្គអំពីកម្រិតកម្ពស់ទឹកទន្លេមេគង្គ និង ទន្លេសាប។ http://www.mrcmekong.org

## ២.៤. សេណារីយ៉ូ គ្រោះមហន្តរាយទឹកជំនន់

នៅរដូវវស្សាព្រះរាជាណាចក្រកម្ពុជា តែងតែទទួលរងនូវសម្ពាធទាបដែលបានកើតឡើងជាបន្តបន្ទាប់ដោយរាប់ចាប់ពីខែមិថុនា ដល់ខែតុលា ដែលបានបង្កឱ្យមានខ្យល់កន្ត្រាក់ និងភ្លៀងធ្លាក់ខ្លាំងនៅទូទាំងផ្ទៃប្រទេស និងក្នុងតំបន់អាងទន្លេមេគង្គ។ ទាំងនេះគឺជាកត្តាដែលធ្វើឱ្យកម្រិតកម្ពស់ទឹកទន្លេមេគង្គ ទន្លេសាបកើនឡើងយ៉ាងគំហុក រួមទាំងមានភ្លៀងធ្លាក់ខ្លាំងនៅតំបន់ជួរភ្នំ និងខ្ពង់រាប។ ដោយឡែកខេត្តដែលតែងទទួលរងគ្រោះធ្ងន់ធ្ងរដោយសារទឹកជំនន់រហ័ស និងទឹកជំនន់ទន្លេ រួមមាន ខេត្តបន្ទាយមានជ័យ បាត់ដំបង ប៉ៃលិន ពោធិ៍សាត់ កំពង់ឆ្នាំង សៀមរាប កំពង់ធំ ព្រះវិហារ ឧត្តរមានជ័យ កំពង់ស្ពឺ កំពត កែប ព្រះសីហនុ កោះកុង កំពង់ចាម ត្បូងឃ្មុំ ក្រចេះ ស្ទឹងត្រែង រតនគិរី ព្រៃវែង កណ្តាល និង តាកែវ...។ល។

[6] មាត្រាទី២១ នៃច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ

| ការសន្ទត់ពីសមត្ថភាព និងឧបសគ្គ | ផលវិបាកផ្នែកមនុស្សធម៌ដែលអាចកើតមាន |
|---|---|
| • ខេត្តមួយចំនួនទទួលរងផលប៉ះពាល់ទាំងទឹកជំនន់ហ៊ស និងទឹកជំនន់ទន្លេ។<br>• ហេដ្ឋារចនាសម្ព័ន្ធនិងផ្លូវថ្នល់ត្រូវបានបំផ្លាញ ដែលជាហេតុធ្វើឱ្យប្រជាពល រដ្ឋពិបាកស្វែងរកសេវាថែទាំសុខភាព អប់រំ និងទីផ្សារ។<br>• តំបន់ខ្លះមិនអាចចូលទៅដល់ដោយសារហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវថ្នល់ត្រូវជនលិចនិងខូចខាត ។<br>• ខូចខាតផ្ទះសម្បែង អគារសាធារណៈ។<br>• មានការផ្លាស់ប្តូរទីលំនៅរបស់ប្រជាពលរដ្ឋទៅកាន់ ទីទួលខ្ពស់ ឬស្នាក់នៅជាមួយសាច់ញាតិ កាន់វត្តអារ៉ាមឬសាលារៀន (កន្លែងមានសុវត្ថិភាព)។<br>• មានគ្រួសារមួយចំនួនមិនអាចចាកចេញពីផ្ទះដែលលិចទឹក ឬខូចខាតរបស់ពួកគេដោយខ្លាចបាត់បង់ទ្រព្យសម្បត្តិរបស់ពួកគេ។<br>• តំបន់សុវត្ថិភាពខ្លះ (ទីទួល) ខ្វះខាតសេវាសុខភាព ទឹកស្អាត អនាម័យ អប់រំ សន្តិសុខសុវត្ថិភាព និងកន្លែងកំសាន្តកុមារ។ល។<br>• សាខាកាកបាទក្រហមកម្ពុជាថ្នាក់ខេត្ត និងកាកបាទក្រហមកម្ពុជាផ្តល់កញ្ចប់ជំនួយដល់គ្រួសាររងគ្រោះគ្រប់ៗគ្នានៅក្នុងរយៈពេល ៧ថ្ងៃប៉ុណ្ណោះ ចាប់ពីពេលប៉ះពាល់ដោយគ្រោះទឹកជំនន់ ហើយតម្រូវការបន្ទាប់មកទៀតគឺអាចនឹងនៅប្រឈម<br>• ប្រជាពលរដ្ឋខ្លះមិនមានជម្រកនៅបណ្តោះអាសន្ន ពេលនៅទីទួល។<br>• ផ្លូវចូលទៅកាន់ទីតាំងមួយចំនួនដែលមានប្រជាពលរដ្ឋស្នាក់នៅ បណ្តោះអាសន្នត្រូវបានកាត់ផ្តាច់។<br>• ការកត់ត្រាព័ត៌មានបញ្ចូលក្នុងប្រព័ន្ធព្រីសឹម មានការយឺតយ៉ាវ និងព័ត៌មាននៅមានកម្រិតពីតម្រូវការមូលដ្ឋានរបស់ជនរងគ្រោះ។<br>• ការសម្របសម្រួលនៅមានកម្រិតក្នុងចំណោមអ្នកពាក់ព័ន្ធនៅមូលដ្ឋានខេត្តនិងថ្នាក់ជាតិ។ | • មានមនុស្សបាត់បង់អាយុជីវិត រងរបួសលើរាងកាយ បាត់បង់លំនៅដ្ឋាន បែកបាក់គ្រួសារ។<br>• កម្រិតហានិភ័យនៃការលង់ទឹកខ្ពស់ជាពិសេសសម្រាប់កុមារ ក្នុងតំបន់ដែលរងគ្រោះ ដោយទឹកជំនន់ហ៊ស។<br>• បាត់បង់ផលដំណាំកសិកម្ម មុខរបរ ប្រាក់ចំណូល ស្បៀងអាហារបម្រុង និងទ្រព្យសម្បត្តិ ដែលបម្រើការរកចំណូលគ្រួសារ សម្រាប់រយៈពេលខ្លី និងពេលវែង។<br>• ទទួលបានតិចតួច ឬមិនអាចទទួលបានសេវាអប់រំ សុខភាព និងទឹកស្អាត។<br>• ទទួលបានតិចតួច ឬ មិនអាចទទួលបានស្បៀងអាហារសម្រាប់គ្រួសារដែលផ្លាស់ប្តូរទីលំនៅ។<br>• មានហានិភ័យលើសុខភាពជាពិសេសចំពោះជំងឺដែលទាក់ទងនឹងទឹក និងជំងឺរាតត្បាតជាសកលនានា។ (ឧ. ជំងឺកូវីត១៩ ជំងឺសា។ល។<br>• មានការកើនឡើងនូវតម្លៃម្ហូបអាហារ។<br>• អាចចូលទៅទីផ្សារបានខ្លះៗ ឬមិនអាចចូលទៅទីផ្សារបានសោះ។<br>• ការកើនឡើងការចំណាកស្រុក ក្នុង និងក្រៅប្រទេស។<br>• មានសញ្ញានៃអំពើហឹង្សារ ការរំលោភបំពាននិងការកេងប្រវ័ញ្ចផ្លូវភេទ។<br>• មានកំណើននៃការខ្ចីបុល ដែលមានអត្រាការប្រាក់ខ្ពស់។<br>• មានតម្រូវការគាំទ្រផ្នែកចិត្តសង្គម។ |

<table>
<tr>
<td>• ពុំមានព័ត៌មានអំពីគ្រួសារដែលផ្លាស់ទីលំនៅទៅនៅជាមួយបងប្អូន ឬអ្នកជិតខាងក្រៅពី ទីទួលសុវត្ថិភាព។<br>• ការងារជម្លៀសប្រជាពលរដ្ឋរងគ្រោះទៅទីទួលសុវត្ថិភាព អាចនឹងមានការប្រឈមជាពិសេសគឺគ្រួសារងាយរងគ្រោះបំផុតដែលនៅដាច់ស្រយ៉ាលពីភូមិដ្ឋាន<br>• ការខូចខាត៖ គឺខូចខាត រោងសិប្បកម្ម ឃ្លាំងទំនិញ តូបអាជីវកម្ម និងទីផ្សារជាដើម។</td>
<td>• ប៉ះពាល់ដល់ការផលិ បរិមាណនៃការផលិតរបស់សិប្បកម្ម ក្រុមហ៊ុន សហគ្រាសត្រូវធ្លាក់ចុះ ដែលនាំឲ្យក្រុមហ៊ុនត្រូវខាតបង់ដោយបណ្តាលមកពីប្រាក់ចំណូលត្រូវបានថយចុះ។</td>
</tr>
<tr>
<td colspan="2">ការវិវត្តនៃសេណារីយ៉ូ</td>
</tr>
<tr>
<td colspan="2">នៅក្នុងប្រទេសកម្ពុជា អាស្រ័យលើតំបន់និងប្រភេទទឹកជំនន់ (ទឹកជំនន់រហ័ស និងទឹកជំនន់ទន្លេ) ទឹកជំនន់គឺមានការវិវត្ត ហើយជាបន្តបន្ទាប់មកទៀត តម្រូវការរបស់ជនរងគ្រោះក៏មានការប្រែប្រួលដែរ។ ដោយសារតែទឹកជំនន់រហ័សកើតឡើងភ្លាមៗ និងមិននឹកស្មានដល់ ដែលជាកត្តាធ្វើឱ្យប្រជាពលរដ្ឋមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការជម្លៀសចេញ បើប្រៀបធៀបទៅនឹងទឹកជំនន់ដែលកើតឡើងយឺតៗ។ មុខរបរអាជីវកម្មខ្នាតតូចជាច្រើនដែលមាននៅតាមមូលដ្ឋានភូមិឃុំត្រូវបានរងផលប៉ះពាល់ ដែលនាំឲ្យបាត់បង់ប្រាក់ចំណូលប្រចាំថ្ងៃរបស់អាជីវករ ដែលតម្រូវឲ្យមានការជួយដោះស្រាយជាកញ្ចប់ថវិកាជំនួយ ឬប្រាក់កម្ចីដើម្បីអាជីវករខ្នាតតូចទាំងនោះអាស្តាជីវភាពនិងសេដ្ឋកិច្ចគ្រួសារបានក្រោយទឹកជំនន់។ ក្នុងអំឡុងពេលទឹកជំនន់ ការផ្លាស់ប្តូរទីលំនៅរបស់ជនរងគ្រោះគឺទៅរកទៅកន្លែងទួលសុវត្ថិភាព ដែលតម្រូវការនៅពេលនោះមានដូចជា ជម្រក ទឹកស្អាតអនាម័យ ស្បៀងអាហារ និងសេវាសុខភាពបឋម។ល។ បន្ទាប់មក ជនរងគ្រោះនិងធ្វើការវិលត្រឡប់ទៅ លំនៅឋានវិញដែលករណីខ្លះគឺលំនៅដ្ឋានពួកគេរងការខូចខាតវិញ។ ក្នុងករណីដែលស្បៀងអាហារនិងផលដំណាំរបស់ជនរងគ្រោះរងការខូចខាត ដោយត្រូវទឹកជន់លិច គឺចាំបាច់ត្រូវធ្វើការចែកស្បៀងអាហារបន្ថែមទៀត ដើម្បីធានាសន្តិសុខស្បៀងរបស់ជនរងគ្រោះរហូតដល់មុខរបររបស់ពួកគេត្រូវបានស្តារឡើងវិញ។ ការទទួលបានទឹកស្អាតអាចត្រូវផ្តល់តាំងពីដំណាក់កាលដំបូង ហើយបន្ទាប់ពីទឹកស្រកទៅវិញគឺការផ្តល់ជូនតាមរយៈការស្តារនិងជួសជុលឬសំអាតប្រភពទឹក។ សកម្មភាពទាំងនេះត្រូវធ្វើឡើងដោយបូកផ្សំជាមួយនឹងការអប់រំផ្សព្វផ្សាយផងដែរ។</td>
</tr>
</table>

## ៣. យុទ្ធសាស្ត្រឆ្លើយតប/ជម្រើសសម្រាប់ការអន្តរាគមន៍

យុទ្ធសាស្ត្រក្នុងការឆ្លើយតបទៅសង្គ្រោះបន្ទាន់គ្រោះមហន្តរាយទឹកជំនន់ នឹងត្រូវអនុវត្តទៅតាមដំណាក់កាលជាអប្បបរមាដែលមានរៀបរាប់ក្នុងនិតិវិធីប្រតិបត្តិស្តង់ដារនៅចំនុច ៣.៣ ខាងក្រោម ។ តាមរយៈនិតិវិធីប្រតិបត្តិស្តង់ដារ យុទ្ធសាស្ត្រក្នុងការឆ្លើយតបគ្រោះមហន្តរាយទឹកជំនន់ជាក់ស្តែងគឺត្រូវបានបង្កើតឡើងនៅកម្រិតខេត្តដែលទទួលរងផលប៉ះពាល់ ដោយផ្អែកលើតម្រូវការនិងភាពចាំបាច់ និងត្រូវបានអនុមត័ដោយថ្នាក់ដឹកនាំ និងក្រុមការងារឆ្លើយតបថ្នាក់រាជធានី-ខេត្ត។

### ៣.១ គោលបំណង

គោលបំណងចំបងនៃយុទ្ធសាស្ត្រឆ្លើយតបនៅថ្នាក់ជាតិគឺ ដើម្បីធានាថាខេត្តដែលទទួលរងគ្រោះដោយគ្រោះមហន្តរាយទឹកជំនន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងនិងឆ្លើយតបទៅនឹងគ្រោះមហន្តរាយឱ្យមានប្រសិទ្ធភាព ជាពិសេស គ្រួសារដែលងាយរងគ្រោះបំផុតទទួលបានគ្រប់គ្រាន់នូវសេវាសុខភាព

ទឹកស្អាត និងអនាម័យខ្លួនប្រាណ ជម្រកស្នាក់នៅបណ្តោះអាសន្ន ការអប់រំ ការការពារសុវត្ថិភាព និងស្បៀងអាហារដើម្បីបំពេញតម្រូវការជាមូលដ្ឋានសម្រាប់ជីវភាពប្រចាំថ្ងៃ ក៏ដូចជាសុខមាលភាពគ្រួសារ និងសង្គម ហើយជាពិសេស ដើម្បីកសាងភាពធន់របស់ពួកគេសម្រាប់ទប់ទល់ទៅនឹងផលប៉ះពាល់គ្រោះទឹកជំនន់នាពេលអនាគត។

## ៣.២ លទ្ធផលរំពឹងទុក

ការរំពឹងទុកចំនួន៧ចំណុច ត្រូវបានដាក់ចេញក្នុងផែនការត្រៀមបម្រុងសម្រាប់ឆ្លើយតបគ្រោះមហន្តរាយទឹកជំនន់សម្រាប់រាជធានី-ខេត្ត រួមមាន៖

- ប្រជាពលរដ្ឋដែលរងគ្រោះដោយទឹកជំនន់ហើយគ្មានឬប្រឈមនឹងការគ្មានជម្រកស្នាក់នៅនឹងទទួលបានការជួយជម្លៀសទៅកាន់ទីទួលសុវត្ថិភាពបានទាន់ពេលវេលា និងមានសុវត្ថិភាព។
- ប្រជាពលរដ្ឋទាំងអស់ដែលរងគ្រោះដោយទឹកជំនន់ហើយដែលស្នាក់នៅបណ្តោះអាសន្ននឹងទទួលបានការការពារសុវត្ថិភាពពីហានិភ័យនានាដែលអាចកើតមានជាយថាហេតុ។
- ប្រជាពលរដ្ឋទាំងអស់ដែលរងគ្រោះដោយទឹកជំនន់ហើយដែលស្នាក់នៅបណ្តោះអាសន្នទទួលបានជម្រកបណ្តោះអាសន្នសមរម្យ សម្រាប់ការស្នាក់នៅបណ្តោះអាសន្ន។
- ប្រជាពលរដ្ឋទាំងអស់ដែលរងគ្រោះដោយទឹកជំនន់ហើយដែលស្នាក់នៅបណ្តោះអាសន្ន ទទួលបានទឹកស្អាតគ្រប់គ្រាន់ សម្រាប់បរិភោគ ប្រើប្រាស់ និងមានអនាម័យ។
- ប្រជាពលរដ្ឋទាំងអស់ដែលរងគ្រោះដោយទឹកជំនន់ហើយដែលស្នាក់នៅបណ្តោះអាសន្នទទួលបានស្បៀងអាហារ ជា អង្ករ គ្រឿងឧបភោគបរិភោគ និងបរិក្ខារចំអិនគ្រប់គ្រាន់។
- ប្រជាពលរដ្ឋទាំងអស់ដែលរងគ្រោះដោយទឹកជំនន់ហើយដែលបានស្នាក់នៅបណ្តោះអាសន្នទទួលបាន សេវាកម្មសុខភាពបឋមនៅនឹងកន្លែង។
- ប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ ទទួលបានព័ត៌មាននានា ពីស្ថានភាពគ្រោះមហន្តរាយទឹកជំនន់ និង ព័ត៌មានចាំបាច់មួយចំនួនពីប្រតិបត្តិការឆ្លើយតប សង្គ្រោះបន្ទាន់ ដែលពាក់ព័ន្ធដល់គេ។

## ៣.៣. នីតិវិធីប្រតិបត្តិស្តង់ដារឆ្លើយតប សង្គ្រោះបន្ទាន់របស់ គ.ជ.គ.ម.

នីតិវិធីប្រតិបត្តិស្តង់ដាក្នុងការឆ្លើយតប សង្គ្រោះបន្ទាន់ គ្រោះមហន្តរាយទឹកជំនន់របស់ គ.ជ.គ.ម. បានសង្ខេបការងារជា៣ ដំណាក់កាលធំៗ ដូចខាងក្រោមនេះ

| **១. ដំណាក់កាលប្រកាសអាសន្ន/ត្រៀមរៀបចំ** | **២. ដំណាក់កាលឆ្លើយតបសង្គ្រោះបន្ទាន់** | **៣.ដំណាក់កាលបិទបញ្ចប់ប្រតិបត្តិការ ឆ្លើយតបសង្គ្រោះបន្ទាន់** |
|---|---|---|
| • ដំណាក់កាលដែលបានទទួលការព្យាករណ៍ថាអាចមានទឹកជំនន់ ពេលខាងមុខ។ | • ដំណាក់កាលដែលកម្ពស់ទឹកជំនន់ដែលបានជនលិចដល់ប្រជាពលរដ្ឋ។ | • ដំណាក់កាលដែលទឹកជំនន់បានស្រកទៅវិញទាំងស្រុង ហើយប្រជាពលរដ្ឋបានវិលត្រលប់ទៅរស់នៅដ្ឋានរួចរាល់។ |

### ៣.៣.១ លក្ខណៈវិនិច្ឆ័យសម្រាប់ការចាប់ផ្តើមអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដាតាមដំណាក់កាល

លក្ខណៈវិនិច្ឆ័យកម្រិតអប្បបរមាខាងក្រោមនេះ ត្រូវបានបង្កើតដោយក្រុមការងារបច្ចេកទេសរបស់ គ.ជ.គ.ម. និងសម្រាប់ប្រើប្រាស់ជាមូលដ្ឋានសម្រាប់ថ្នាក់ដឹកនាំគ.ជ.គ.ម. និងក្រសួង ស្ថាប័នពាក់ព័ន្ធ ធ្វើការសម្រេចចិត្ត ចាប់ផ្តើមអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់ការងារត្រៀមរៀបចំ ការឆ្លើយតបសង្គ្រោះបន្ទាន់ និងការបិទបញ្ចប់ ប្រតិបត្តិការ តាមដំណាក់កាលដែលបានសង្ខេបខាងលើ។

#### ៣.៣.១.១ ដំណាក់កាលប្រកាសអាសន្ន/ត្រៀមរៀបចំ

ការចាប់ផ្តើមអនុវត្តការងារសម្រាប់ដំណាក់កាលប្រកាសអាសន្ន/ត្រៀមរៀបចំបាន គឺត្រូវតែយោងតាមស្ថានភាពព្រឹត្តិការណ៍ ឬគ្រោះថ្នាក់ទាំងឡាយណាដែលត្រូវទៅនឹងលក្ខណៈវិនិច្ឆ័យមួយ ឬច្រើនក្នុងចំណោមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- មានការព្យាករណ៍ថាគ្រោះមហន្តរាយទឹកជំនន់អាចនឹងកើតឡើងដល់កម្រិតប្រកាសអាសន្ននៅតាមស្ថានីយ៍វាស់កម្ពស់ទឹក (មើលតារាងខាងក្រោម) នៅក្នុងពេល ១ ទៅ ២ខែខាងមុខ។
- មានខេត្តចំនួន២ខេត្តឡើងទៅដែលប៉ាន់ប្រមាណថាទឹកជំនន់ខិតទៅរកចំនុចប្រកាសអាសន្ននឹងរងគ្រោះដោយគ្រោះមហន្តរាយទឹកជំនន់។
- ការប៉ាន់ប្រមាណចំនួនគ្រួសារដែលទទួលរងផលប៉ះពាល់ច្រើនជាង៣០% នៃចំនួនគ្រួសារសរុបទូទាំងប្រទេស។

| ឈ្មោះស្ថានីយ៍ជលសាស្រ្ត | កម្រិតប្រកាសអាសន្ន(វាស់កម្ពស់ទឹកគិតជាម៉ែត្រ) | | | | |
|---|---|---|---|---|---|
| | កម្រិតមិនមានភាពអាសន្ន និងនិមិត្តសញ្ញា | កម្រិតប្រកាសអាសន្ន និងនិមិត្តសញ្ញា | | កម្រិតទឹកជំនន់ និងនិមិត្តសញ្ញា | |
| ទន្លេមេគង្គ ស្ទឹងត្រែង | ⬇ ⬆ | ១០៧០. | ⬇ ⬆ | ១២០០. | ⬇ ⬆ |
| ទន្លេមេគង្គ ក្រចេះ | | ២២០០. | | ២៣០០. | |
| ទន្លេមេគង្គ កំពង់ចាម | | ១៥២០. | | ១៦២០. | |
| ទន្លេចតុមុខ ភ្នំពេញ | | ១០៥០. | | ១២០០. | |
| ទន្លេសាប កំពង់ផែភ្នំពេញ | | ៩៥០. | | ១១០០. | |
| ទន្លេបាសាក់ កោះខែល | | ៧៤០. | | ៧៩០. | |
| ទន្លេមេគង្គ អ្នកលឿង | | ៧៥០. | | ៨០០. | |
| ទន្លេសាប ព្រែកក្តាម | | ៩៥០. | | ១០០០. | |

#### ៣.៣.១.២ ដំណាក់កាលឆ្លើយតបសង្គ្រោះបន្ទាន់គ្រោះមហន្តរាយទឹកជំនន់កម្រិតជាតិ

ការចាប់ផ្តើមអនុវត្តការងារសម្រាប់ដំណាក់កាលឆ្លើយតបសង្គ្រោះបន្ទាន់នៅកម្រិតជាតិបានគឺត្រូវតែយោងតាមស្ថានភាពព្រឹត្តិការណ៍ ឬគ្រោះថ្នាក់ទាំងឡាយណាដែលត្រូវទៅនឹងលក្ខណៈវិនិច្ឆ័យមួយ ឬច្រើនក្នុងចំណោមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- មានការស្នើសុំជួយអន្តរាគមន៍ឆ្លើយតបពីគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានីខេត្ត (វិសាលភាពនៃផលប៉ះពាល់លើសពីសមត្ថភាពខេត្តក្នុងការដោះស្រាយ)។

- មានចំនួនគ្រួសារប៉ះពាល់ ច្រើនជាង ៣០% នៃចំនួនគ្រួសារសរុបនៅក្នុងប្រទេស (របាយការណ៍ស្ដីពីផលប៉ះពាល់ និងតម្រូវការទាញចេញពីប្រព័ន្ធព្រឹសឹម។
- ប្រព័ន្ធគ្រប់គ្រងថ្នាក់ក្រោមជាតិ ចំពោះខេត្តដែលបានទទួលរងនៃការប៉ះពាល់ធ្ងន់ធ្ងរ ប៉ុន្តែខេត្តនោះមិនអាចដឹកនាំសកម្មភាពគ្រប់គ្រង និងឆ្លើយតបគ្រោះមហន្តរាយបាន។
- ទទួលការណែនាំពីរាជរដ្ឋាភិបាលចុះអន្តរាគមន៍ផ្ទាល់នៅមូលដ្ឋានខេត្តដែលកំពុងរងគ្រោះ។

#### ៣.៣.១.៣. ដំណាក់កាលបិទបញ្ចប់ប្រតិបត្តិការឆ្លើយតបសង្គ្រោះបន្ទាន់

ការចាប់ផ្ដើមអនុវត្តការងារសម្រាប់ដំណាក់កាលបិទបញ្ចប់ប្រតិបត្តិការឆ្លើយតបសង្គ្រោះបន្ទាន់ បានគឺត្រូវតែយោងតាមស្ថានភាពព្រឹត្តិការណ៍ ឬគ្រោះថ្នាក់ទាំងឡាយណាដែលត្រូវទៅនឹងលក្ខណៈវិនិច្ឆ័យមួយ ឬច្រើនក្នុងចំណោមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- ការព្យាករណ៍កម្រិតទឹកជំនន់នៅស្ថានីយ៍ទាំងអស់នៃដងទន្លេមេគង្គលើ កណ្ដាល និងស្ថានីយ៍ទាំងអស់ក្នុងប្រទេសកម្ពុជា បញ្ជាក់ថា ទឹកបានស្រក និងបន្តស្រកនៅក្រោមកម្រិតព្រមាននិងមិនមានសញ្ញាថា ទឹកនឹងឡើងវិញ។

## ៣.៤. ការអនុវត្តដំណាក់កាលនីមួយៗនៃនីតិវិធីប្រតិបត្តិស្តង់ដា គ.ជ.គ.ម.

### ៣.៤.១. ដំណាក់កាលប្រកាសអាសន្ន/ត្រៀមរៀបចំ (មុនពេលទឹកជំនន់)

| ជំហានការងារចំបងៗតាម លំដាប់លំដោយពេលវេលា | នីតិវិធី/សកម្មភាពអប្បបរមាដែលត្រូវអនុវត្ត | អ្នកទទួលខុសត្រូវដឹកនាំអនុវត្ត |
|---|---|---|
| ការត្រៀមរៀបចំ មុនរដូវវស្សាមកដល់ (ខែមករា - ឧសភា ) | **រៀបចំនិងអនុម័តយន្តការដឹកនាំប្រតិបត្តិការឆ្លើយតបគ្រោះមហន្តរាយ៖**<br>• កំណត់ជ្រើសរើសមន្ត្រីសម្រាប់បណ្ដុះបណ្ដាល និងបំពេញមុខងារតាមផ្នែកនីមួយៗនៃរចនាសម្ព័ន្ធដឹកនាំប្រតិបត្តិការឆ្លើយតបគ្រោះមហន្ត-រាយ។<br>• បណ្ដុះបណ្ដាលអំពីតួនាទី និងការទទួលខុសត្រូវ ជំនាញបច្ចេកទេសតាមផ្នែក នឹងធ្វើតេស្តអនុវត្តសាកល្បង។<br>• *(ឧបសម្ព័ន្ធទី១៖ យន្តការប្រតិបត្តិការឆ្លើយតបគ្រោះមហន្តរាយ)* | អគ្គលេខាធិការដ្ឋានក្រោមកិច្ចអន្តរាគមន៍ពីអនុប្រធានទី១ គ.ជ.គ.ម. |
| | **រៀបចំអនុវត្តកម្មវិធីពង្រឹងសមត្ថភាពដល់មន្ត្រីលេខាធិការដ្ឋាន និងក្រុមការងារគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូផ្សេងៗ ៖** | |

| | | |
|---|---|---|
| | • អនុវត្តលំហាត់សាកល្បងឆ្លើយតបសង្គ្រោះបន្ទាន់គ្រោះមហន្តរាយទឹកជំនន់ដោយប្រើប្រាស់ផែនការត្រៀមបម្រុងសម្រាប់ឆ្លើយតបសង្គ្រោះបន្ទាន់គ្រោះទឹកជំនន់ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ<br>• ពង្រឹងក្រុមការងារចុះសិក្សាប៉ាន់ប្រមាណរហ័សរបស់ គ.ជ.គ.ម.(CAM-RAT) និងមានតំណាងមកពីលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយក្រសួង ស្ថាប័នផ្សេងៗ(តាមវិស័យ) តាមរយៈធ្វើការត្រួតពិនិត្យឡើងវិញអំពីតួនាទី និងភារៈកិច្ចក្នុងការទទួលខុសត្រូវរបស់សមាជិកនីមួយៗ និងបំពាក់សម្ភារៈ<br>• ពង្រឹងសមត្ថភាពក្រុមរុករក និងសង្គ្រោះថ្នាក់ជាតិចំនួន៦កងរបស់គ.ជ.គ.ម. សម្រាប់ឆ្លើយតបទៅនឹងឧប្បត្តិហេតុផ្សេងៗដែលអាចកើតឡើងជាយថាហេតុទៅតាមតំបន់ដែលបានកំណត់ក្នុងការទទួលខុសត្រូវ។ | ប្រធាននាយកដ្ឋានប្រតិបត្តិការឆ្លើយតបសង្គ្រោះបន្ទាន់និងស្តារឡើងវិញ<br><br>ប្រធាននាយកដ្ឋានអប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាល |
| | **រៀបចំកិច្ចប្រជុំជាមួយមន្ត្រីមកលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយនៃក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ដើម្បី៖**<br>• ពិភាក្សារៀបចំជាស្រេចតារាងព័ត៌មានពីទីតាំងប្រតិបត្តិការ (3Ws-អ្នកណា? ធ្វើអ្វី? ធ្វើនៅកន្លែងណា?)។<br>• ពិភាក្សា រៀបចំផែនទីចង្អុលបង្ហាញ(Dashboard) រួមស្តីអំពីសម្ភារៈបរិក្ខារ និងភស្តុភារ (ទឹក និងអនាម័យ ស្បៀងអាហារ សុខភាព ជម្រក អប់រំ និងការគាំពារ) ដែលអង្គការដៃគូ ក៏ដូចជាក្រសួងពាក់ព័ន្ធ បានត្រៀមបម្រុងទុកសម្រាប់ការឆ្លើយតបសង្គ្រោះគ្រោះមហន្តរាយ ដែលនឹងបង្ហាញអំពីទីតាំង នៅតាមរាជធានី-ខេត្ត និងសម្ភារៈបរិក្ខារ និងភស្តុភារលម្អិតដែលបានរក្សាទុក រួមនឹងអ្នកទទួលបន្ទុក។<br>• ចែករំលែកផែនការត្រៀមបម្រុងដែលបានរៀបចំជាស្រេចសម្រាប់ឆ្លើយតបសង្គ្រោះបន្ទាន់គ្រោះមហន្តរាយទឹកជំនន់។ | អគ្គលេខាធិការដ្ឋាន គ.ជ.គ.ម. |

| | | |
|---|---|---|
| | **ជូនដំណឹងដល់មន្ត្រីលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយតាមក្រសួងពាក់ព័ន្ធទាំងអស់ដើម្បី៖**<br>• ចាប់ផ្តើមដឹកនាំអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដាតាមវិស័យសម្រាប់សកម្មភាពនៅដំណាក់កាលត្រៀមរៀបចំមុនគ្រោះមហន្តរាយកើតឡើង។ | អគ្គលេខាធិការ<br>គ.ជ.គ.ម. |
| អនុវត្តនីតិវិធីប្រតិបត្តិស្តង់ដាដំណាក់កាលព្រមាន/ត្រៀមរៀបចំ (ពេលមានការព្រមានជាក់លាក់) | **រៀបចំកិច្ចប្រជុំជាមួយមន្ត្រីមកពីលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ នៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ដើម្បី៖**<br>• ធ្វើការវាយតម្លៃអំពីស្ថានភាពគំរាមកំហែងដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងចំណុច(៣.៣.១)នៃផែនការនេះ។<br>• ស្នើសុំការអនុម័តពីអនុប្រធានទី១ គ.ជ.គ.ម. ចាប់ផ្តើមអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដា (អាស្រ័យលើស្ថានភាព និងលទ្ធផលនៃកិច្ចប្រជុំ)។ | អគ្គលេខាធិការ<br>គ.ជ.គ.ម. |
| | • ធ្វើរបាយការណ៍ពីស្ថានភាពគំរាមកំហែងដោយទឹកជំនន់ជាក់ស្តែងជូន អគ្គលេខាធិការដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំ គ.ជ.គ.ម. រៀងរាល់ថ្ងៃសុក្រនៃចុងសប្តាហ៍ក្នុងករណីមិនមានគ្រោះមហន្តរាយ និង រៀងរាល់ ២៤ម៉ោងម្តង ក្នុងករណីមានគ្រោះមហន្តរាយកំពុងកើតឡើង២៤ម៉ោងម្តង។ | ប្រធាននាយកដ្ឋានព័ត៌មានគ្រប់គ្រងគ្រោះមហន្តរាយ |
| | **រៀបចំសំណើដាក់ជូនថ្នាក់ដឹកនាំ គ.ជ.គ.ម.**<br>• ធ្វើការស្នើរសុំដល់រាជរដ្ឋាភិបាលផ្តល់អន្តរាគមន៍ស្នើដល់ក្រសួងដែលពាក់ព័ន្ធដាក់បញ្ជូនក្រុមការងារបច្ចេកទេសតំណាងក្រសួងនីមួយៗ ចូលក្នុងក្រុមការងារប្រតិបត្តិការឆ្លើយតបគ្រោះមហន្តរាយដែលត្រូវដឹកនាំដោយអគ្គលេខាធិការ គ.ជ.គ.ម. ឬចាត់តាំងដោយថ្នាក់ដឹកនាំ គ.ជ.គ.ម. | អគ្គលេខាធិការក្រោមកិច្ចអន្តរាគមន៍ពីអនុប្រធានទី១<br>គ.ជ.គ.ម. |
| | **ដឹកនាំកិច្ចប្រជុំជាមួយក្រុមការងារប្រតិបត្តិការឆ្លើយតបគ្រោះមហន្តរាយ៖**<br>• បែងចែកភារៈកិច្ច ការទទួលខុសត្រូវតាមផ្នែកនីមួយៗនិង កំណត់គោលដៅ/ទីតាំងទទួលខុសត្រូវរបស់ក្រុមនីមួយៗ<br>• ត្រួតពិនិត្យផែនការត្រៀមបម្រុងដើម្បីធានាថាគ្រប់ព័ត៌មានទាំងអស់មានសុពលភាពប្រើប្រាស់បាន។ | អគ្គលេខាធិការ<br>គ.ជ.គ.ម. |

| | | |
|---|---|---|
| | **ដឹកនាំកិច្ចប្រជុំជាមួយដៃគូអភិវឌ្ឍន៍ ៖**<br>• ដើម្បីធ្វើបច្ចុប្បន្នភាពសភាពការណ៍ដែលកំពុងកើតមាន<br>• ជូនដំណឹងដល់ដៃគូរអភិវឌ្ឍន៍ អំពីរចនាសម្ព័ន្ធសម្របសម្រួលឆ្លើយតបគ្រោះមហន្តរាយរបស់រាជរដ្ឋាភិបាលនៅក្នុងកម្រិតថ្នាក់នីមួយៗ<br>• សម្របសម្រួលបង្កើតតារាងធនធានត្រៀមបម្រុងសម្រាប់ការឆ្លើយតបក្នុងករណីចាំបាច់។ | អគ្គលេខាធិការ គ.ជ.គ.ម. |
| | **ការត្រៀមកងម្លាំងអន្តរាគមន៍ គ.ជ.គ.ម.៖**<br>• រៀបចំកងកម្លាំងចម្រុះនិងបែកចែកភារកិច្ចត្រៀមចុះជួយជម្លៀសគ្រួសារដែលងាយរងគ្រោះទៅកាន់ទីទួលសុវត្ថិភាពពីទឹកជំនន់ ក្នុងករណីមានការស្នើសុំដោយខេត្តរងគ្រោះ។<br>• រៀបចំកងកម្លាំងចម្រុះត្រៀមចុះប្រចាំការនៅតាមទីតាំងដែលស្នើសុំដោយខេត្ត។<br>• រៀបចំក្រុមគ្រូពេទ្យសង្គ្រោះបឋមត្រៀមសម្រាប់ការឆ្លើយតប សង្គ្រោះបន្ទាន់តាមការស្នើសុំរបស់ខេត្ត។ | អគ្គលេខាធិការ គ.ជ.គ.ម. និងលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយក្រសួងការពារជាតិ និងក្រុមសម្របសម្រួលក្រុមរុករក និង សង្គ្រោះ គ.ជ.គ.ម. |

### ៣.៤.២. ដំណាក់កាលឆ្លើយតប សង្គ្រោះបន្ទាន់គ្រោះមហន្តរាយទឹកជំនន់

គួរបញ្ជាក់ថាក្រៅពីសកម្មភាពការងារឆ្លើយតបសង្គ្រោះបន្ទាន់ជាក់ស្តែង ទាំងអស់ខាងក្រោម ជាការចាំបាច់ដែលក្នុងដំណាក់កាលឆ្លើយតបសង្គ្រោះបន្ទាន់នេះ គ.ជ.គ.ម. នឹងសហការជាមួយស្ថាប័នជាដៃគូក្នុងការរៀបចំឱ្យមានការថតវិសាលភាពទឹកជំនន់តាមរយៈប្រព័ន្ធផ្កាយរណប ឱ្យបានទៀតទាត់ ចាប់ពីពេលជន់លិចរហូតដល់ស្រកទៅវិញ យ៉ាងហោចណាស់ឱ្យបានមួយសប្តាហ៍ម្តង (តែអាស្រ័យតាមស្ថានភាពជាក់ស្តែងនៃទឹកជំនន់) សម្រាប់ជាមូលដ្ឋានឯកសារ ក្នុងការងារត្រៀមបម្រុងក្នុងឆ្នាំបន្តបន្ទាប់។

| ដំណាក់កាល (ម៉ោង) | នីតិវិធី/សកម្មភាពអប្បបរមាដែលត្រូវអនុវត្ត | អ្នកទទួលខុសត្រូវដឹកនាំអនុវត្ត |
|---|---|---|
| រយៈពេល ២៤ម៉ោង បន្ទាប់ពីទទួលបានការស្នើសុំអន្តរាគមន៍ពី គ.គ.ម.ខ. | • ប្រើប្រាស់ប្រព័ន្ធព្រីសឹម(PRISM)ដើម្បីទាញយកទិន្នន័យប៉ាន់ប្រមាណចំនួនគ្រួសារដែលប៉ះពាល់ទំហំនៃផលប៉ះពាល់ ការខូចខាតនិងធ្វើរបាយការណ៍ប៉ាន់ប្រមាណពីតម្រូវការជូនថ្នាក់ដឹកនាំ គ.ជ.គ.ម. | ប្រធាននាយកដ្ឋានព័ត៌មានគ្រប់គ្រងគ្រោះមហន្តរាយ |
| | • ក្រុមការងារចុះសិក្សាប៉ាន់ប្រមាណរហ័សចុះសហការណ៍ជាមួយមេខាធិការដ្ឋានថ្នាក់ខេត្ត ស្រុក និង | អគ្គលេខាធិការនិងក្រុមការងារសិក្សាប៉ាន់ |

| | | |
|---|---|---|
| | ឃុំ សិក្សាពីផលប៉ះពាល់ ខូចខាត និងតម្រូវការ និងធ្វើការបូកសរុបផលប៉ះពាល់ខូចខាតនិងតម្រូវការជាក់ស្តែងរួមជាមួយនឹងសំណើសុំអន្តរាគមន៍ដែលបានដាក់ស្នើជូនដល់ថ្នាក់ដឹកនាំគ.ជ.គ.ម.សម្រេច។ | ប្រមាណ (CAM-RAT) របស់គ.ជ.គ.ម. |
| | **សម្របសម្រួលកិច្ចប្រជុំជាមួយអន្តរក្រសួងពាក់ព័ន្ធទៅនឹងតម្រូវការដែលបានស្នើដោយគ.គ.ម.ខ. រួមជាមួយរបាយការណ៍ពីក្រុមការងារប៉ាន់ប្រមាណរហ័សថ្នាក់ជាតិ៖**<br>• ពិភាក្សាអំពីធនធានដែលក្រសួងមានសម្រាប់ការបំពេញបន្ថែមសម្រាប់ធ្វើការឆ្លើយតបទៅនឹងតម្រូវការរបស់ខេត្ត។<br>• ផ្តល់ជាយុទ្ធសាស្ត្រដល់ក្រុមការងារគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងក្រសួង ស្ថាប័ន នីមួយៗធ្វើការសម្របសម្រួលបជាមួយដៃគូអភិវឌ្ឍន៍។ | អគ្គលេខាធិការគ.ជ.គ.ម. និងក្រុមប៉ាន់ប្រមាណរហ័សថ្នាក់ជាតិ |
| | **ស្នើសុំការអនុញ្ញាតពីថ្នាក់ដឹកនាំកំពូល គ.ជ.គ.ម. កោះប្រជុំមន្ត្រីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ដើម្បី៖**<br>• បង្ហាញរបាយការណ៍ការវាយតម្លៃអំពីស្ថានភាពគ្រោះមហន្តរាយ។<br>• ពិភាក្សា និងសម្រេចលើយុទ្ធសាស្ត្រនិងផែនការសម្រាប់ឆ្លើយតបទៅនឹងតម្រូវការដែលបានរកឃើញនិងដាក់ស្នើដោយ គ.គ.ម.ខ.។<br>• សម្របសម្រួលកៀរគរនិងធ្វើតារាងធនធាន។<br>• កំណត់តារាងព័ត៌មានពីទីតាំងប្រតិបត្តិការ (3Ws) ដែលដៃគូអភិវឌ្ឍនានាដែលមានបំណងចូលរួមក្នុងប្រតិបត្តិការឆ្លើយតប។<br>• កំណត់ ពេលវេលាសម្រាប់កិច្ចប្រជុំសម្របសម្រួលនាពេលបន្តបន្ទាប់ ។ | អគ្គលេខាធិការគ.ជ.គ.ម. និងក្រុមប៉ាន់ប្រមាណរហ័សថ្នាក់ជាតិ |
| | **ក្នុងករណីពិសេស និងចាំបាច់ គ.ជ.គ.ម.ត្រូវ៖**<br>• រៀបចំគោលការណ៍ស្នើ សុំការអនុញ្ញាតពីរាជរដ្ឋាភិបាលពិភាក្សាក្នុងការប្រកាសដាក់ប្រទេស/ខេត្ត/តំបន់ក្នុងស្ថានភាពអាសន្នគ្រោះមហន្តរាយ។<br>• រៀបចំគោលការណ៍ស្នើសុំការអនុញ្ញាតពីរដ្ឋាភិបាលស្នើសុំជំនួយពីដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ និងភ្នាក់ងារសហប្រជាជាតិដើម្បីបំពេញបន្ថែមនូវធនធានដែលមានស្រាប់សម្រាប់ឆ្លើយតបទៅនឹងតម្រូវការ។ | អគ្គលេខាធិការក្រោមកិច្ចអន្តរាគមន៍ពីអនុប្រធានទី១គ.ជ.គ.ម. |

| | | |
|---|---|---|
